បាឋកថា

Talk

# កំណើតរដ្ឋសម័យមុនអង្គរ ៖
# លទ្ធផលដំបូងនៃការស្រាវជ្រាវនៅថាឡាបរិវ៉ាត់

# Pre-Angkorian State Formation:
## Preliminary Results of the Thala Borivat Archaeological Project

in Khmer and English

ដោយ ហេង ពិភាល់ by Heng Piphal



ថ្ងៃសុក្រ ទី១០ ខែកក្កដា ឆ្នាំ២០១៥ ម៉ោង៥:៣០ល្ងាច

នៅសាលសម្ដែងក្នុងមហាវិទ្យាល័យបុរាណវិទ្យា នៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ

Friday, July 10, 2015, 5:30pm at RUFA (behind the National Museum)

**សូមអញ្ជើញចូលរួមស្ដាប់ដោយមេត្រី**

---

វិភាគទានពី with contribution from

- សប្បុរសជន
- សមាជិកយសោធរ
- មិត្តយសោធរ

- Individuals
- Members of Yosothor
- Friends of Yosothor

yosothor@gmail.com www.yosothor.org

# កំណើតរដ្ឋសម័យមុនអង្គរ ៖

## លទ្ធផលដំបូងនៃការស្រាវជ្រាវនៅថាឡាបរិវ៉ាត់

ដោយ ហេង ពិភាល់

នៅដើមស.វ.ទី៧ សិលាចារឹកមាននិយាយអំពីក្សត្របីអង្គគឺព្រះបាទភវវរ្ម័ន, មហេន្ទ្រវរ្ម័ន, និងឦសានវរ្ម័ន។ អ្នកស្រាវជ្រាវទម្លាប់ហៅ សម័យដែលគ្របដណ្តប់ស.វ.ទី៧-៨ថា «សម័យមុនអង្គរ» រីឯចិនវិញចាប់ផ្តើមហៅរដ្ឋនោះថា «ចេនឡា»។ ក្រៅពីសិលាចារឹក មានសំណល់ប្រាង្គប្រាសាទនិងបុរាណវត្ថុជាច្រើនដែលទាក់ទងផ្ទាល់ទៅនឹងសាសនា ចំណែកឯហេដ្ឋារចនាសម្ព័ន្ធស៊ីវិលផ្សេងៗក៏គេមានប្រទះឃើញខ្លះៗដែរ។ ប៉ុន្តែគេដឹងស្តួចស្តើងនៅឡើយអំពីលំនៅស្ថាន ព្រមទាំងជីវិតរាល់ថ្ងៃរបស់មនុស្ស។

ក្នុងក្របខ័ណ្ឌគម្រោង «បុរាណវិទ្យានៅថាឡាបរិវ៉ាត់» យើងខ្ញុំបានធ្វើកំណាយច្រើននៅឆ្នាំ២០១១-២០១៤។ ឯទិន្នន័យដំបូងដែលបានមក មានមួយចំនួនដែលអាចឲ្យយើងធ្វើការបកស្រាយអំពីការវិវឌ្ឍសង្គម, សេដ្ឋកិច្ច និងនយោបាយពីសម័យបុរេប្រវត្តិតមកដល់សម័យមុនអង្គរ។ យើងអាចឲ្យឈ្មោះដល់រយៈពេលនៅចន្លោះនោះថា «សម័យអន្តរកាល» ដោយសម្តៅពីស.វ.ទី៣ដល់ស.វ.ទី៦ ហើយកស្តុតាងនៃឥទ្ធិពលឥណ្ឌា ជាពិសេសក្នុងវិស័យសាសនាចាប់ផ្តើមមកតាំងពីស.វ.ទី៥។

# Pre-Angkorian State Formation:

## Preliminary Results of the ThalaBorivat Archaeological Project

by Heng Piphal

By the 7th c. CE,epigraphy highlights three successive kings:BhavavarmanI, Mahendravaman, and Iśānavarman. The period from the 7th to 8th c., known to scholars as “pre-Angkorian period”, corresponds to a State called “Chenla” in different Chinese accounts. Thanks to an important inscription corpus, the period is well known for its religious architecture and statuary. However archaeological evidence of civil infrastructure, mundane activities and settlement system is yet to be explored.

The ThalaBorivat Archaeological Project includes surveys and excavations between 2011-2014. Our preliminary results suggest socioeconomic and political change and continuity from the protohistoric to the pre-Angkorian period that occurred during what could be called “transition period” (c. 3th - 6th c. CE). There is also evidence of the adoption of Indic religions that occurred during the 5th century.